ទូរសព្ទពោទ៍ ហាន់ដាពង្រឹងស្មារតីមកវិញព្រោះស្គាល់ថាជាសុងសក្តិ ។ នាងគ្រហែមយកសំឡេងឱ្យប្រក្រតីសិនមុនពេលចុចទទួល៖

«សុំទោសផងសុងសក្តិ! ថ្ងៃនេះមានរឿងមិនល្អកើតឡើងតែលែងអីហើយ! អស់អីហើយ ស្អែកជួបគ្នានៅពេទ្យណា៎ ចាំខ្ញុំបកស្រាយណាកុំខឹងអី ខ្ញុំមានហេតុផលពិតមែន ដែលមិនបានលើកទូរសព្ទ!»

នាងដាក់ឧបករណ៍ចុះ ជួនពេលម្ដាយលើកទឹកក្រូចថ្លុងមកដល់។

«ស្អែកត្រូវចូលធ្វើការមែនទេដា? តែម្ដាយចង់ទៅមើលកោះបន្ដិច បើសិនអាចទៅបាន!»

នាងដកដង្ហើមធំបង្ហាញទុក្ខកង្វល់ក្នុងចិត្ត ។ បើនារីចំណាស់ម្នាក់នេះ ពុំមែនមនុស្សដែលខ្លួននឹងរំលែកទុក្ខព្រួយពិគ្រោះយោបល់បាន តើជាអ្នកណាវិញ?

«ម៉ាក់!»

«មានរឿងអីកូន? តាំងពីមកដល់ឃើញឈរនៅហ្នឹងអត់ងូតទឹកអត់រកបាយទឹកអី?!»

«គ្រួសារខាងប្តីខ្ញុំមកដល់ស្ទឹងត្រែងច្រើនគ្នាណាស់!»

នាងបញ្ឈប់ត្រឹមណោះ តែចិត្តនឹកព្រួចដល់បងថ្លៃម្នាក់នោះ។ នាងមិននិយាយអំពីគេទេបើទោះជាវត្តមានគេជាគ្រឿងនាងបារម្ភផុតលេខក៏ដោយ។

«ហើយពួកគេឥឡូវស្នាក់នៅឯណាកូន មានការអី?!» ម្ដាយថាតបមកវិញ ទាំងបើកភ្នែកភ្លឹះៗបញ្ចេញសេចក្តីព្រួយបារម្ភ។

នាងធ្វើមុខស្ងួតសម្លឹងគាត់វិញដោយមិនចេញស្តីអ្វី។ ភាពស្ងៀមស្ងាត់របស់ហាន់ដា ធ្វើឱ្យស្ត្រីចំណាស់ងក់ក្បាលមួយៗទាំងតឹងចិត្ត គាត់និយាយឱ្យយោបល់ទៅនាងវិញ៖

«គេមិនសុខចិត្តមែនទេកូន? គេចង់បានរបស់គេវិញ! បើថាតឹងតែងហើយ ឱ្យគេវិញទៅរបស់ដែលមិនមែនជាកម្មសិទ្ធិយើង។»

«ក៏មិនមែនរបស់ពួកគេដូចគ្នាម៉ាក់! វាជាកេរចុងក្រោយដែលសិដ្ឋឱ្យកូនរក្សាទុក! បើពួកគេមានសិទ្ធិសិដ្ឋមិនផ្ញើនៅនឹងយើងទេ!»

នាងបែរចំហៀងយឺតៗ លបមើលប្អូនប្រុសកម្លោះដែលកំពុងអង្គុយប្រមូលលេងបណ្ដារង្វាន់បងស្រីបានទិញពីភ្នំពេញមកផ្ញើ។

«សុខភាពនិវត្តមិនអីទេ?!»

នាងសួរទាំងដឹងស្រេចហើយនូវចម្លើយថា គេនេះមិនជាសះស្បើយរហូតតទៅ។ នាងសួរព្រោះចង់ដកឃ្លាទាញប្រធានបទចាកចេញពីរឿងទ្រព្យគេរទាំងនោះមួយខណៈ ហាក់បីដូចជាទុកខ្យល់អុកស៊ីសែនខ្លះឱ្យដល់ខ្លួនឯងដើម្បីដក។

## ប្រុសស្អាតក្បែរខ្លួន

ពេញមួយយប់ ធីតាយើងមិនអាចធ្មេចបានស្កប់ទេ។

នាងបិទហ្វេសប៊ុក បិទបណ្ដាញទាក់ទងនានា កាច់ចោលសូម្បីលេខទូរសព្ទ ព្រោះការភ័យខ្លាចអាថ៌កំបាំងមួយគ្មានហេតុនិងផលពិត។

«នីដាក៏ដោយហាន់ដាក៏ដោយ ! គេជាប្រពន្ធខ្ញុំ ជាមនុស្សខ្ញុំឱបជាប់ទ្រូង ! មរតកគេ កិត្តិយសគេ ជាមរតកខ្ញុំនិងកិត្តិយសខ្ញុំ! អ្នកណាមិនសុខចិត្តចង់តតាំងជាមួយគេ ត្រូវតតាំងជាមួយខ្ញុំ!»

លោកហ្នឹងហើយដែលខ្ញុំត្រូវខ្លាចបំផុតនោះគឺម៉ាល់។ នាងនិយាយម្នាក់ឯងផងពេលដៃចុចលើកុំព្យូទ័រស្រាវជ្រាវអំពីឈ្មោះគេ។ នាងវាយ Kemal ។ ភាសាអារ៉ាប់ប្រែថា កិត្តិយសកំពូល តែអ្នកដែលពាក់ឈ្មោះនេះ មិនបានធ្វើអ្វីគិតដល់កិត្តិយសទេ។

ហាន់ដាគ្រវីក្បាលយឺតៗ មាត់រអ៊ូ៖

«មិនទំនងនឹងឈ្មោះអីបន្តិច!»

«ថាឱ្យអ្នកណា?!»

គឺជេនមកដល់។ នាងដឹងថាគេឮពាក្យរវើរវាយរបស់នាង តែមិនបកស្រាយទេ។ ស្រីស្អាតស្រវាបិទហើយងាកទៅរកវារកឯកសារសំខាន់ៗក្រោមតុមកបង្ហាញពីមុខគេ។ បុរសនេះអង្គុយចុះមកយ៉ាងស្និទ្ធស្នាលពីមុខស្រី។ គេមានកិរិយាស្និទ្ធដល់កម្រិតដែលអាចថា បើគឺម៉ាល់បានឃើញអាចបែកទ្រូងស្លាប់។

ហាន់ដាហុចសំណុំឯកសារទៅឱ្យជេនហើយនិយាយខ្សឹបៗ៖

«នៅនេះទាំងអស់ជេន!»

ជេនឈ្ងោកទាញមកពិនិត្យម្ដងមួយៗ។

«ច្បាស់ហើយថាជេនព្យួរការងារប៉ូលិសព្រោះខ្ញុំ!»

ជេនងើបមុខមាត់ស្រស់សង្ហាសម្លឹងស្រីទាំងកែវភ្នែកអាសូរ។ គេគិតចុះឡើងមុនពេលឆ្លើយច្បាស់លាស់មាំទាំ ៖

«កុំភ័យរឿងនៅភ្នំពេញ ខ្ញុំចាត់ការឱ្យ!»

«ឯកសារគ្រប់គ្រងសណ្ឋាគារទាំងនេះ កុំឱ្យរបូតទៅពួកគេនោះបាន!»

នាងផ្តាំបន្ថែមដោយកែវភ្នែកកង្វល់ខ្វល់ខ្វាយពន់ពេក។ ជេនងក់ក្បាលៗផ្ទក់ប្រមូលឯកសារទុកខណៈសំឡេងម្តាយនាងហៅល្ងើយៗ ៖

«សុងសក្តិ ញ៉ាំកាហ្វេសិនទេ មីងឆុងភ្លាម!»

សុងសក្តិមិនដឹងមកដល់តាំងពីថ្មើរម៉ានទេ សំខាន់ជេននិងហាន់ដារលះរលាំងរៀបឫកពាឡើងវិញមួយរំពេចហាក់មិនចង់ឱ្យអ្នកដែលទើបនឹងបានមកដល់នេះ ដឹងឮអ្វីៗដែលពួកគេទើបតែបាននិយាយគ្នាមុននេះឡើយ។

សុងសក្តិជាបុរសមាឌធំសជ្រះ និងមានទឹកមុខស្រស់ស្រាយ។ គេបង្ហាញខ្លួននៅក្បែរទ្វារជាហេតុបណ្តាលឱ្យហាន់ដានឹកពីភាល់ភ្លាមថា ប្រសិនមុននេះម្តាយនាងមិនហៅគេ នាងមិនដឹងថាគេមកដល់តាំងពីថ្មើរណានោះផង។

ជេនក្រោកឡើងជាមួយកញ្ចប់ឯកសារ។

ទោះបីសុងសក្តិរៀបឫកយ៉ាងណាជេននៅតែមើលដឹងថា គេលួចដៀងមកពិនិត្យពិច័យសំណុំឯកសារក្នុងដៃនាយ។

ដូច្នោះហើយបានជាពេលចេញបាត់ទៅឆ្ងាយជេននៅតែឆ្លៀត SMS មករកហាន់ដាជាមួយឃ្លាបញ្ជាក់ខ្លីថា៖

«ម្នាក់មិញនេះ មិនបាច់យកចិត្តថ្លើមគិតទេ! ចេញមកដឹងតែមានគំនិតមិនល្អតែម្តង!»

នារីកំពុងអង្គុយក្នុងឡានជាមួយសុងសក្តិដំណើរឆ្ពោះទៅកាន់មន្ទីរពេទ្យ។ នាងឃើញសាររបស់ជេនក៏ដឹងថាបុរសទាំងទ្វេមិនត្រូវរ៉ូវគ្នា ព្រោះរឿងអ្វីដែរ។ នាងសើចស្ងួតម្នាក់ឯងជាសញ្ញាថា អត់មានពេលគិត ព្រោះចិត្តកំពុងស្មុគស្មាញរឿងអ្នកផ្ទះអតីតស្វាមីនោះគ្រប់ហើយ ។

«មិត្តជិតខាងរបស់នីដា ចេញចរិតមកឆ្មើងឆ្មៃ ខ្ញុំខំសើចដាក់...!»

សុងសក្តិរអ៊ូមិនទាន់ផុតផងនារីនិយាយកាត់គេ៖

«កុំខ្វល់ជាមួយគាត់! តាំងពីតូចមក នៅម៉្ញុំនោះជេនមិនលេងចូលអ្នកណាទាំងអស់ ដល់ធំឡើងមកក៏និយាយរករាប់អានតែខ្ញុំម្នាក់ដែរ!»

«ចម្លែកៗមនុស្សចម្លែក!»

គេរអ៊ូតិចៗ តែនាងយល់ចិត្តគេ ដឹងថានាយនេះកំពុងតាមដាន ស៊ើបអំពីទំនាក់ទំនងនាងជាមួយជេន ។ ហាន់ដានិយាយពង្វាង៖

«ថ្ងៃនេះទៅហាត់ការដំបូង រាងភ័យៗ!»

បុរសនេះឆ្លៀតឱកាសលូកដៃមកកាន់ប្រអប់ដៃនាង ។ មិនត្រឹមតែមិនអ្នកអានមិនព្រមទេ សូម្បីតែហាន់ដាក៏មិនព្រមដែរ នាងដកដៃចេញភ្លាមៗ។

សុងសក្កិហាក់អៀនអន់នឹងការបដិសេធទាន់ហន់នេះ។ គេនិយាយបន្លប់បរិយាកាសបានភ្លាមៗដូចគ្នា៖

«មានខ្ញុំហើយមិនបាច់ខ្លាចពេទ្យណាទាំងអស់!»

«ដឹងហើយថាសុងសក្កិជាលោកដុកទ័រល្បី! ដុកទ័រធំ!»

នារីខំប្រឹងពោលបន្លប់វិញដូចគ្នា តែចិត្តនឹកដល់បុរសម្នាក់ឈ្មោះសិដ្ឋ។ បុរសម្នាក់ដែលបានស្រឡាញ់នាងអស់ពេញមួយជីវិតគេ តែមិនដែលសូម្បីបំពានពាក្យសម្ដីមកលើខ្លួន កុំថាឡើយដល់លូកលាន់ប៉ះពាល់។ គេរៀបការតែមិនបានទទួលសិទ្ធិជាស្វាមីគ្រប់យ៉ាងទេ។ ចិត្តនាងសង្វេគអាណោចអាណិត មិនដឹងត្រូវធ្វើយ៉ាងណា ប្រើវិធីណា ការពារគ្រួសារ ក្រុមហ៊ុនគេ ឱ្យស្មើនឹងសមានចិត្តដែលគេមានមកឱ្យនាង។

ដោយគ្មានបំណងផង នាងនឹកឃើញដល់បងប្រុសរបស់គេ។  មនុស្សនោះមើលទៅស្រស់សង្ហាដូចតួកុនអឺរ៉ុប ចិត្តថ្លើមសមណាស់តែទូលំទូលាយទៅតាមមាឌកម្ពស់កំពររបស់គេ មិនសមណាមានចរិតផ្លាស់ប្ដូរចុះឡើងច្រើនសណ្ឋានដូចមនុស្សត្រូវអារក្ខចេញចូល។

«ម្សិលមិញដាជិះទូកអ្នកណាមក!»

សុងសក្កិលបតាមដាននាងក៏ឆ្លៀតឈ្លេចសួរ។ នាងមិនអាចលាក់បាំងបានទេ ទើបនិយាយមួយៗ៖

«បងថ្លៃខ្ញុំ បងប្រុសធំរបស់ពិសិដ្ឋ!»

សុងសក្តិមើលទៅមិនភ្ញាក់ផ្អើលសោះ។ ហាន់ដាកាន់តែយល់ថា រឿងកាលពីនៅលើទូកនោះត្រូវបានអ្នកផ្ទះនោះនិយាយគ្នាប្រាប់គេឯងគ្មានសល់ទេ។

ដោយអារម្មណ៍ទោមនស្សនាងវាចាតិចៗ៖

«ពួកគេមិនសប្បាយចិត្តរឿងមរតកហ្នឹងទេ ម៉ាក់ក្មេកខ្ញុំក៏ប្រដេញទូកមកទៀត!»

សុងសក្តិសួរបកវិញ៖

«ចុះដាគិតម៉េច?»

«បើបងប្រុសគេម្នាក់នោះចង់មើលថែអាជីវកម្ម មុខរបរគ្រួសារគេ ម្តាយខ្ញុំថា យើងដកខ្លួនឱ្យទៅគេវិញទៅ! យើងមិនបានកើតមក យករបស់អស់នោះមកតាមទេ!»

ទូរសព្ទនាងរោទ៍។ នាងលើកទទួលនិយាយ ទាំងមិនបានចាប់អារម្មណ៍ថាសុងសក្តិយល់បែបណាចំពោះរឿងមរតកនិងរឿងសាច់ថ្លៃ របស់នាងនោះទេ។

«សក្តិ អ៊ំសុផានថា នៅកោះមានកើតករណីបាត់ថ្នាំ!»

សុងសក្តិក្រឡេកមកសម្លឹងភាពស្លន់ស្លោលើទឹកមុខនាង។ ដើរតួជាសុភាពបុរសចិត្តល្អ ជាជំនាញរបស់គេស្រាប់ហើយ គេនិយាយលួង៖

«ឈប់ភ័យ! ចាំខ្ញុំទៅដោះស្រាយ! ខ្ញុំទៅជាមួយនីដា!»

នារីក្តោបទូរសព្ទទាំងក្តីបារម្ភថ្មីចូលមកលុកលុយផ្លូវចិត្ត......

## ដំណឹងចាក់ស្រេះ

ភាពស្រស់ស្អាតមួយសម្រាប់ជីវិតគីម៉ាល់ គឺការធ្វើដំណើរក្នុងល្បឿនលឿនស្លេវ។ អំណាចនៃអារម្មណ៍រំភើប និងរហ័សរហួន កុងកាច់ខ្លួនឯង បញ្ឆាចង្កូតពត់ពេនប្រជែងកម្លាំងដៃជាមួយចង្អូរទឹកជាខ្សែត្រវេញខ្ទួលខ្ទាញ់  ជាអាថ៌កំបាំងមួយសម្រាប់លុបដានស្នាមឈឺចាប់នានាចេញពីឱរ៉ាប្រុសស្អាតភ្លាមៗយ៉ាងស័ក្តិសិទ្ធិ។

«បងគីម៉ាល់បើកអូប័រ ធ្វើដូចបិទភ្នែកបើកឡានលើគោក!»

វុធជញ្ជក់មាត់សរសើរមេកោយ ខណៈអ៊ុនតាមមើលសកម្មភាពបុរសនេះដោយស្ងប់ស្ងៀម។ តាមរបៀបជាច្រើន បច្ចេកទេសនៃការបញ្ជាទូកលើសមុទ្រ និងដងទន្លេមិនដូចគ្នាទេ។ ពីចំណុចមួយទៅ

ចំណុចមួយទៀតតែងជាសិល្បៈ ដែលទាមទារការអនុវត្តផ្តោតអារម្មណ៍និងសមត្ថភាពក្នុងការទទួលយកការប្រណាំងទង្គិចជាមួយខ្យល់ដែលយើងមិនបានថ្មីកព្រោះមិនដែលបានមកដល់ទីនេះ។

«គាត់ជាតួឯករបស់យើង!»

អ៊ុននិយាយតិចៗទាំងប្រតោងគែមអូប័រព្រោះខ្សែទឹកផ្លាស់ប្តូរនៅផ្នែកខាងមុខទាមទារការបណ្តែតនិងបត់បែន

«ឯងមកណេះវុធ!»

«បាទបង!»

«នៅរាល់ពេលកាច់ចង្កូត ងាកចេញពីបន្ទាត់ត្រង់ ទម្ងន់ត្រូវសម្រាល ! ទោះឈរឬអង្គុយឯងត្រូវនៅឱ្យចំទីតាំងល្អ  ខ្ពស់ពីលើទឹក ហើយមើលឃើញឱ្យឆ្ងាយ បំផុតតាមដែលអាចធ្វើបាន! ជិះដល់នេះឯងត្រូវមើលឃើញ៥០ម៉ែត្រទៅមុខ! ក្រៅពីឃើញទេសភាពយើងអាចសម្គាល់ដំណើរខ្យល់! ធម្មតាបើខ្យល់បញ្ច្រាសខ្លាំងសម្គាល់ជើងយើងដែលជាន់នេះថាមាន កន្ត្រាក់ខ្លាំង រញ្ជ័រដែរ?!»

ច្រមុះវែងស្រួចរបស់គេនៅក្រោមវ៉ែនតា Audi ប្រណីតបន្ថែមអំណាចអាថ៌កំបាំងនៃថាមពលទាក់ទាញសម្រាប់បុរសនេះ។ អ៊ុនក្រឡេកឃើញនាយ ក៏នឹកឃើញដល់ព័ត៌មានជាច្រើនជុំវិញនារីដែលនាយកំពុងចាប់ចិត្ត។

អ៊ុនមិនដឹងថាគួរនិយាយចំណុចណា លាក់បាំងត្រង់ណានោះទេ តែចុងក្រោយពេលពួកគេសំចតលើកោះ រៀបចំសន្ទូច គេដាច់ចិត្តនិយាយ។

«បង! អ្នកផ្ទះនៅភ្នំពេញឱ្យព័ត៌មានច្បាស់ការមកថា ហាន់ដារៀបការជាមួយបងសិដ្ឋតែ មិនសូវដែលនៅផ្ទះទេ!»

នេះជាព័ត៌មានដែលប៉ះពាល់ផ្លូវចិត្តគីម៉ាល់បំផុត។

គេងាកសម្លឹងវុធដែលកំពុងចំតិតចតរូបត្រី ចិត្តគេវិលវល់នឹកភ្នកដល់ផ្ទៃមុខនិងបបូរមាត់ស្រីស្អាតដែលកាលពីម្សិលស្ថិតក្រោមលង្វែកទ្រូង។

គេមិនមាត់ ដូចទុកពេលឱ្យអ៊ុនរាយការណ៍អំពីព័ត៌មានដែលគេទំនងដូចមិនសូវចង់បង្ហើប តែក៏មិនហ៊ានលាក់។

«មានអ្នកបន្ទោសថាបងសិដ្ឋចុងក្រោយផឹកស្រារាល់ថ្ងៃសម្លាប់ខ្លួនឯងចោល!»

គីម៉ាល់លូកដៃដកវ៉ែនតាចេញ ហើយងាកមកសម្លឹងម្ចាស់ព័ត៌មាន។

អ៊ុនមិនអាចបង្អង់យូរទេគេ និយាយបន្ថែមដោយចុចទូរសព្ទបង្ហាញឯកសារ៖

« គេមានListទិញស្រា ដែលចុងក្រោយនេះសូម្បីតែពេទ្យសុខុមជាពេទ្យប្រចាំផ្ទះ ក៏បានព្រមានបងសិដ្ឋដែរ!»

ដោយតៀ្បតវ៉ែនតាទៅនឹងកអាវ គីម៉ាល់ឆ្លើយតបជាមួយអ៊ុនទាំងបែរទៅសម្លឹងកម្ពស់ទឹកកណ្ដាលទន្លេឆ្ងាយសន្លឹម៖

«សំឡេងអាសិដ្ឋដែលផ្ញើមកទាំងអស់នៅឯណា?!»

«នៅឌូបៃ បងឯងខឹងបោះចោលទៅក្នុងទឹកហើយហ្នឹង!»

គេស្រាប់តែឮពាក្យរាយការណ៍កើតសៅហ្មងក្នុងចិត្ត តែគីម៉ាល់អត់ធ្មត់រង់ចាំឱ្យគ្រប់យ៉ាងត្រូវបានបញ្ជាក់សិន។ ប្រសិននាងជាមូលហេតុធ្វើឱ្យប្ដីស្លាប់ នាងនឹងដឹងគ្នាជាមួយគេ តែគេក៏ស្រាប់តែចង់ដឹងថា ក្រៅពីផ្ដែផ្ដាំឱ្យខ្លួនថែរក្សាគេប្រពន្ធ សារសំលេងជាច្រើនទៀត ពិសិដ្ឋបាននិយាយអ្វីខ្លះ? មានអាថ៌កំបាំងអ្វីទៅ ដែលគេចង់ប្រាប់បងខ្លួនឯង។ ស្ដាយណាស់ព្រោះចិត្តមានះរបស់ខ្លួនគ្រាមុន មិនព្រមស្ដាប់ មិនព្រមដឹងឮរហូតដល់មានរឿងថ្នាក់នេះកើតឡើង។

«ចាំខ្ញុំទាក់ទងទៅឌូបៃរកវិធីហៅសារអស់នោះឡើងមកវិញ!» អ៊ុនបន្ថែម។

គីម៉ាល់ងក់ក្បាល៖

«ពួកឯង កុំពូកែយកសម្ដីតាយឹមនិងប្រពន្ធចុងប៉ាខ្ញុំ មកទុកជាការពិតពេក! ពួកអស់នោះមិនដែលនិយាយពិត មិនដែលនិយាយល្អពីអ្នកណាទេ!»

បុរសនេះថាចប់គេក្រោកដើរចេញទៅទាំងសៅហ្មង។ ដៃគេទាញកាមេរ៉ាសំណព្វយកទៅជាមួយ តែអ៊ុនយល់ថាចិត្តគេមិនបាននៅជាមួយទេសភាពពិតប្រាកដទេ។

មាត់គេនិយាយការពារ តែចិត្តគេក៏កំពុងតែមិនស្រណុក។

ព័ត៌មាននានាកំពុងបាននឹងបំផ្លាញដំណើរផ្សងព្រេងដ៏រីករាយ លើដងទន្លេស្រស់ស្រងាត់មួយនេះ។

គេរត់តាមពីក្រោយរាងកាយស្រស់សង្ហាត្រឹកៗហើយខ្សឹបៗប្រាប់បន្ថែម៖

«មុនរៀបការ បងសិដ្ឋបានវេលុយ៧០ម៉ឺនដុល្លារមកឱ្យហាន់ដា!»

គីម៉ាល់ឈប់ដំណើរដៀងភ្នែកមកមើលគូកន។ អ៊ុនលេបទឹកមុខនិយាយបន្ថែម៖

«ខ្ញុំឆែកអស់ហើយ នេះជាការពិត! អ្នកណាក៏ថាហាន់ដាមិនបានស្រឡាញ់បងសិដ្ឋ ហើយដើរចោលផ្ទះមកស្ទឹងត្រែងរហូត! មកម្តងៗរាប់អាទិត្យ!  បងសិដ្ឋនៅម្នាក់ឯង ក្នុងផ្ទះដែលទិញក្រោយរៀបការរួច!»

«ព្រឹកមិញគ្នាយើងតាមដានឃើញ ប្រពន្ធបងសិដ្ឋ នៅពេទ្យពេញមួយថ្ងៃជាមួយពេទ្យល្បីឈ្មោះម្នាក់ឈ្មោះសុងសក្តិ! បណ្តើរគ្នាស្អិតរមួតដូចមិនមែនមនុស្សមានប្តីទើបនឹងស្លាប់»

វុធបន្ថែមមកម្តង។ ពួកគេមានភារកិច្ចស៊ើបពីប្រភពខុសគ្នានិងប្រធានបទផ្សេងគ្នា។ អ្វីដែលក្រុមវុធកំពុងតាមដាន គឺសកម្មភាពហាន់ដាពេលនេះ ចំណែកខាងអ៊ុនរុករក គឺសកម្មភាពហាន់ដាកាលពីមុនពេលប្តីស្លាប់។

គីម៉ាល់ទម្លាក់ភ្នែកសម្លឹងរលកទឹក។ គេចាប់ផ្តើមសកម្មភាពថតរូប តែចិត្តរត់ថយក្រោយរាប់ពាន់នាទីបកទៅនឹកឃើញដល់រូបថតបុរសសប្បុរសលើអេក្រង់របស់នាងកាលពីម្សិល។

អាម្នាក់នោះនៅក្រចេះទេ ម្តេចឡើងមកដល់ស្ទឹងត្រែងបានពីព្រលឹមល្មម្លេះ?

គេគិតផង ត្រចៀកនៅផ្ទៀងស្តាប់ពាក្យរាយការណ៍បន្តផង។ ឃើញឫកពាថៅហ្វាយ វុធនិយាយបន្ថែម៖

«ពេលទៅ ទៅជាមួយឡានពេទ្យកម្លោះហ្នឹង! ដល់ថ្ងៃត្រង់ចេញមក មកជាមួយប៉ូលិសជេន ម្នាក់ពីម្សិលដែលទៅទទួលនៅផែ!»

គីម៉ាល់ក្រោកឡើង ហើយដើរមួយៗចាកចេញ។ គេដោះស្បែកជើង ដើរកាត់ផ្ទៃទឹករាក់ៗពេញដោយកម្រាលល្បប់លាយគ្រាប់គ្រួសគ្រប់ពណ៌។ ទីនេះច្បាស់ណាស់នឹងលាក់កំបាំងនូវជម្រកត្រីហែលច្រវាត់កម្រនឹងឃើញ។

ពេលបុរសទៅដល់គោលដៅ គេនៅផ្ទង់ចុចគ្រឹបៗយកទិដ្ឋភាពហ្វូងមច្ឆាក្រោមស្រទាប់ជលសាថ្លាយង់ មនុស្សជំនិតទាំងពីរនៅបន្តការសន្ទនាពីក្រោយខ្នងល្វើយៗ......

«អាមួយពេទ្យហ្នឹងបានសមសង្ស័យជាងអាមួយប៉ូលីស! រៀបការហើយភ្លាម ប្រពន្ធបងសិដ្ឋយកម្នាក់ហ្នឹងទៅធ្វើជំនួយការផ្ទាល់នៅភ្នំពេញ ហើយឱ្យមើលថែសុខភាពអ្នកក្នុងផ្ទះទៀត! ពេទ្យសុខុមធ្លាប់ជាពេទ្យប្រចាំគ្រួសារក៏អន់ចិត្តដែរ! មិនបានប៉ុន្មាន អាម្នាក់ឈ្មោះសុងសក្តិនេះមានលុយរាប់ម៉ឺនសង់វីឡានៅស្ទឹងត្រែង អាឡូវមានឯកសារលបលួចទិញដីចម្ការកាហ្វេបានរាប់សិបហិកតាទៀត! ទិញលួចលាក់អត់ចេញមុខទេ!»

គីម៉ាល់ចងចិញ្ចើម។

គេមិនបានស្រមៃនឹកដល់មុខមនុស្សគេស្អប់ទេ តែគេនឹកដល់នាង។

សកម្មភាពនាងពេលដែលលើកទូរសព្ទរបស់សុងសក្តិម្តងៗខ្ទប់ផង បាំងផង ខ្លាចគេឮហើយក្រោកដើរចេញឆ្ងាយៗ។

«ហាន់ដា! កុំឱ្យសោះ កុំឱ្យអាគីម៉ាល់រកឃើញការពិតខ្មៅៗអស់នោះ!»

គេនិយាយស្ងាត់ក្នុងចិត្តទាំងមុខស្លួតជ្រប់ម្នាក់ឯង។

**ចំណង**

នៅឯណោះ ម្តាយនាងវិញកំពុងតែពេញចិត្តខ្លាំងឡើងៗនូវវត្ថុនិងសម្ភារៈជាជំនូនបន្តបន្ទាប់របស់សុងសក្តិ។

«លើកក្រោយមិនបាច់ចំណាយទិញទៀតទេក្មួយ លើកមុនហូបមិនទាន់អស់ផងសុងសក្តិ!»

ម្តាយនីដាពិតជាពេញចិត្ត ចំពោះសភាពតាមចែចង់របស់បុរសនេះមកលើកូនស្រីមេម៉ាយរបស់គាត់។

«ល្ងាចនេះខ្ញុំចេញពីការងារភ្លាមឡើងទូកជូនមីងគេ ទៅកោះមើលមជ្ឈមណ្ឌលភ្លាម!»

«អ៊ីចឹងញាំបាយថ្ងៃត្រង់ទេ? មីងរៀបចំជុំគ្នា!»

សុងសក្តិបានចិត្តណាស់គេមានគម្រោងការភ្លាមៈ

«មន្ទីរពេទ្យរវល់ណាស់! ដកខ្លួនមិនបានទេ មានពេលកន្លះម៉ោងអីហូបបាយឆក់កណ្តៀតហ្នឹង! អ៊ីចេះទៅ យើងរៀប Dinner នៅកោះតែម្តងទៅ ល្អទេមីង?!»

គេនេះមានចេតនាចង់បង្កើតឈុតឆាកឱ្យខាងស្រីទន់ចិត្ត។ ស្ត្រីចំណាស់ដឹងច្បាស់ណាស់ ដូច្នេះហើយពេលល្ងាចភ្លាម ខាងស្រីកំពុងរៀបចំសម្ភារៈ ថ្នាំពេទ្យយកទៅកោះ អ្នកម្តាយឆ្លៀតចូលមកបន្ទប់នាងជាមួយទឹកមុខស្រស់ស្រាយ។

«កូនអ្ហាជាមនុស្សស្រី ឡើងចុះ ផ្លូវទឹកញឹកញាប់ គួរមានតែម្នាក់ណាដែលអាចការពារ និងចេញមុខការលំបាកៗឱ្យយើងបាន!»

នាងងាកមករកម្តាយ ភ្នែកក៏មើលហួសទៅក្រោមផ្ទះឃើញឡានសុងសក្តិនៅទីនោះ។គេកំពុងរៀបចំសម្ភារៈផ្សេងៗ។ នាងដឹងថាម្តាយកំពុងសម្តៅទៅលើប្រធានបទមួយដែលនាងហាក់គ្មានអារម្មណ៍ស្ម័គ្រនឹងស្តាប់ផង កុំថាឡើយយកមកគិត។

«យើងមានជេនហើយ!»

នាងថាខ្លីៗព្រមទាំងក្រោកប្រមូលកុំព្យូទ័រ។ ម្ដាយក្រោកយឺតៗមកតាម។ គាត់ជួយប្រមូលខ្សែភ្លើង និងសៀវភៅពេទ្យ មាត់ក៏នៅតែបន្តបញ្ចុះបញ្ចូលៈ

«ក្រែងជេនត្រូវធ្វើការធំដុំនៅភ្នំពេញនោះអី? »

«នៅនេះការតូចៗយើងរ៉ាប់រងខ្លួនឯងបាន!»

«កុំមាត់រឹងមើលកូន!»

នាងងាកមកសម្លឹងម្ដាយ រួចដៀងហួសទៅរក បុរសនៅខាងក្រោមកំពុងតែជួយបាញ់ទឹកផ្កាផង សម្អាតឡានគេរង់ចាំនាងនឹងម្ដាយផង។ ទឹកមុខម្ដាយគឺពេញចិត្តចំពោះគេណាស់។

«រកឯណាបាន?! រៀនបានខ្ពង់ខ្ពស់ សុភាពរាបសារកាយសម្បទាល្អ សម្ដីសំដៅថ្លៃថ្នូរ គោរពមនុស្សស្រី!»

ម្ដាយនិយាយធ្វើឱ្យនាងរវេភ្នែកមកសម្លឹងក្ដារកម្រាលផ្ទះ។ នារីមិនចង់បន្ទោសតែនាងរំឭកតិចៗៈ

«ប្ដីខ្ញុំទើបតែស្លាប់បានជាងមួយខែទេម៉ាក់!»

ម្ដាយដកដង្ហើមធំ គាត់គិតចុះឡើងទើបដាច់ចិត្តនិយាយៈ

«អ្នកណាក៏ដឹងថាកូនឯងនិងពិសិដ្ឋ មិនមែនជាប្ដីប្រពន្ធ...!»

«ម៉ាក់កុំនិយាយរឿងហ្នឹងទៀត!»

នាងនិយាយកាត់ភ្លាមព្រោះមិនចង់ឱ្យគាត់បញ្ចប់។ ទូរសព្ទរោទ៍ ។ សំឡេងនេះមកចំពេលល្អព្រោះមិនចង់ឮអ្នកណានិយាយរំឭក អំពីរឿងចាស់របស់ខ្លួនជាមួយស្វាមីកម្សត់ឡើយ។

«និវត្តទៅណា? ម៉េចទុកទូរសព្ទចោល វាមិនទៅកោះទេ?!»

នាងលើកនិយាយៈ

«ជម្រាបសួរ! រកនិវត្តមែនទេ?»

«បងនីដា! ខ្ញុំរកបងសិដ្ឋឃើញហើយ!»

ហាន់ដាបើកភ្នែកធំៗ។

ភ្លាមៗនោះនាងគិតមិនយល់ទេ តែរកសំណួរសួរក៏មិនចេញ។ និវត្តរកឃើញប្ដីដែលស្លាប់បាត់របស់នាងតាមរបៀបណា?

ទូរសព្ទរលត់ វីដេអូខលលេចឡើងពេលចិត្តនាងកំពុងជ្រួលច្រាល់។

ហាន់ដាចុចទទួល។ នៅពីក្រោយស្នាមញញឹមរបស់ប្អូនប្រុសនាង ពិតណាស់នាងឃើញមនុស្សដែលអាចធ្វើឱ្យនិវត្តប្រទ្បាំថាជាបងថ្លៃខ្លួន។

គេកំពុងឈរចង្ក្រាងញញឹមមករកកែវភ្នែកមូលក្រឡង់របស់ខាងស្រី។

«គីម៉ាល់!»

នាងហៅឈ្មោះគេខ្សឹបៗ រួចងាកក្រោយខ្នងឃើញម្ដាយកំពុងទាញខោអាវបត់ដាក់វ៉ាលិស។ ស្រីស្អាតខ្ទប់កាមេរ៉ារត់ចេញមកក្រៅបន្ទប់ឆ្ងាយពីគេ មុនពេលនិយាយបន្ត៖

«គីម៉ាល់ប្អូនខ្ញុំមានស្មារតីមិនគ្រប់ដូចអ្នកដទៃទេ កុំធ្វើអីវា!»

គីម៉ាល់ដើរមកក្បែរ ខណៈនិវត្តនៅតែញញឹម។

«និវត្តឈប់ថត បងចង់និយាយជាមួយគេនោះ!»

នាងបង្គាប់ទៅប្អូនទាំងខាំមាត់តិចៗ។ ស្រស់ស្រីចុចបិទវីដេអូហើយចុចខលនិយាយ។ ខាងប្រុសលើកទូរសព្ទនាងទាំងមិនចេញស្ដីថាយ៉ាងណា ធ្វើឱ្យទ្រូងស្រីត្រូវតឹងសឹងប្រេះបាន។

«គីម៉ាល់ ប្រុងធ្វើអី?!»

គេសើចតិចៗមុនឆ្លើយ៖

«មួយភ្លែតសោះហៅឈ្មោះបីដងហើយ! នឹកអីនឹកម៉េះ?!»

ហាន់ដាឆ្លើយតបទាំងឆ្អែតចិត្ត៖

«ប្អូនខ្ញុំនៅកន្លែងណា?!»

«កន្លែងយើងត្រូវជួបគ្នាល្ងាចនេះ! ឆាប់ភ្លេចម៉េះ? អាល័យរៀបចំខ្លួនហ្មែន?!

នាងធូន់ចិត្តត្បិតមានកង្វល់ ។ មិនស្មានថា គេយកសម្ដីនោះជាការយ៉ាងនេះសោះ។ រហូតដល់នាងភ្លេចសួនក្សថា នឹងមានរឿងអីកើតឡើងបើមិនទៅតាមណាត់។

ស្រីស្អាតដកដង្ហើមយូរបន្ធូរភាពតឹងតែង ទើបរកពាក្យមកឆ្លើយដាច់ៗ៖

«ខ្ញុំ...ខ្ញុំមានធុរៈ! ទៅមិនបានទេ!»

«ស្រេចតែចិត្ត!»